# ការពិតអំពីជម្ងឺរបេង (TB)

**Tuberculosis (TB) Facts (Khmer)**

## ការបង្ហាញអំពី *TB*

## តើអ្វីទៅជា TB ?

“TB” គឺជាអក្សរកាត់របស់ជម្ងឺមួយដែលមានឈ្មោះថា ជម្ងឺរបេង ។ TB សាយភាយក្នុងខ្យល់ពីមនុស្សម្នាក់ទៅមនុស្ស ម្នាក់ទៀត ។ មេរោគរបេង (TB) ឆ្លងតាមរយៈខ្យល់ នៅពេល នរណាម្នាក់ ដែលមាន**ជម្ងឺរបេង**សួត ឬឈឺបំពង់ក ក្អក និយាយ សើច ច្រៀង ឬកណ្តាស ។ អ្នកដែលនៅក្បែរអ្នក**ជម្ងឺរបេង** អាចស្រូបខ្យល់មានមេរោគរបេង TB ចូលទៅក្នុង សួតរបស់ពួកគេ ។ មេរោគរបេង (TB) អាចរស់នៅក្នុងរាង កាយរបស់លោកអ្នកដោយមិនធ្វើឲ្យលោកអ្នកឈឺ ។

គេហៅថា **ការចម្លងរបេង (TB) ដ៏ស្ងៀមស្ងាត់** ។ នេះមាន ន័យថាាកអ្នកមានផ្ទុកតែមេរោគរបេង (TB) អសកម្ម ( សម្ងំ ) នៅក្នុងរាងកាយរបស់លោកអ្នកប៉ុណ្ណោះ។ មេរោគ អសកម្មនេះ មិនអាចឆ្លងទៅលើមនុស្សម្នាក់ផ្សេងទៀតបាន នោះទេ ។ ប៉ុន្តែ ប្រសិនបើមេរោគទាំងនេះ បានវិវឌ្ឍន៍ពេញ លក្ខណៈ ឬក្លាយជាសកម្មក្នុងរាងកាយរបស់លោកអ្នក និងកើនឡើងច្រើន លោកអ្នកនឹងឈឺដោយសារ **ជម្ងឺរបេង (TB)** ។

នៅពេលមេរោគរបេង (TB) ធ្វើសកម្មភាព ( កើនឡើង ច្រើនក្នុងរាងកាយរបស់លោកអ្នក ) គេឲ្យឈ្មោះវាថា **ជម្ងឺរបេង (TB)** ។ មេរោគទាំងនេះជាធម្មតាវាយប្រហារទៅលើសួត ។ ពួកវាអាចវាយប្រហារទៅលើផ្នែកផ្សេងៗទៀតនៃរាងកាយ ផងដែរដូចជា ក្រលៀន ខួរក្បាល ឬឆ្អឹងខ្នង ។ **ជម្ងឺរបេង (TB)** នឹងធ្វើឲ្យលោកអ្នកឈឺ ។ អ្នក**ជម្ងឺរបេង (TB)** អាចចម្លងមេរោគ នេះទៅ អោយមនុស្សដែលពួកគេចំណាយពេលនៅជាមួយ ជារៀងរាល់ថ្ងៃ ។

## តើខ្ញុំឆ្លងមេរោគរបេង (TB) តាមរបៀបណា ?

លោកអ្នកអាចឆ្លងមេរោគរបេង (TB) ប្រសិនបើលោកអ្នក ចំណាយពេលនៅក្បែរអ្នក**ជម្ងឺរបេង**សួត ឬឈឺបំពង់ ក ។ លោកអ្នកអាចឆ្លង ដោយការដកដង្ហើមចូលនូវមេរោគរបេង (TB) តែម្យ៉ាងគត់ ដែលអ្នកជំងឺក្អកក្នុងបរិយាកាស ។ លោកអ្នកមិនអាចឆ្លងរោគរបេង (TB) ពីសំលៀកបំពាក់របស់ នរណាម្នាក់ កែវផឹកទឹក គ្រឿងប្រដាប់ញុំាអាហារ ការចាប់ដៃ បង្គន់ ឬកន្លែងផ្សេងៗទៀត ដែលអ្នកជម្ងឺរបេង(TB) ស្ថិតនៅ នោះឡើយ ។

## តើខ្ញុំដឹងដោយវិធីណា ប្រសិនបើខ្ញុំបានឆ្លងមេរោគរបេង (TB) ?

ប្រសិនបើលោកអ្នកបានប្រាស្រ័យទាក់ទងជាមួយអ្នកដែល មាន**ជម្ងឺរបេង (TB)** លោកអ្នកគួរតែទៅជួបវេជ្ជបណ្ឌិតរបស់ លោកអ្នក ឬមណ្ឌលសុខភាពក្នុងតំបន់របស់លោកអ្នក ដើម្បី ធ្វើតេស្ត ។

ការធ្វើតេស្តមានពីររបៀប ដែលអាចត្រូវបានប្រើប្រាស់ ដើម្បីជួយស្រាវជ្រាវរក**ការឆ្លងរោគរបេង (TB) ៖** ការធ្វើតេស្តស្បែករករោគរបេង(TB) ឬការធ្វើតេស្តឈាមរករោគរបេង(TB) ។ ការធ្វើតេស្តស្បែក ត្រូវបានគេប្រើប្រាស់ញឹកញាប់បំផុត ។ ម្ជុលតូចមួយត្រូវបានប្រើប្រាស់ដើម្បីដាក់ សម្ភារៈធ្វើតេស្តមួយចំនួន ដែលឲ្យឈ្មោះថា tuberculin នៅ ក្រោមស្បែក ។ ក្នុងរយៈពេល 2-3 ថ្ងៃ លោកអ្នកត្រូវត្រឡប់ ទៅរកបុគ្គលិកថែទាំសុខភាព ដែលនឹងត្រួតពិនិត្យ ដើម្បី រកមើល ថាតើមានប្រតិកម្មចំពោះការធ្វើតេស្ត ឬយ៉ាងណា ។ ក្នុងករណីខ្លះ ការធ្វើតេស្តឈាមរករោគរបេង(TB) ត្រូវបានគេ ប្រើប្រាស់ ដើម្បីធ្វើតេស្តរកមើល**ការឆ្លងរោគរបេង** (TB) ។ ការធ្វើតេស្តឈាមនេះ វាស់ពីរបៀបដែលប្រព័ន្ធផ្សុំារបស់ មនុស្សម្នាក់ មានប្រតិកម្មជាមួយមេរោគដែលបង្កឲ្យកើតរបេង (TB) ។

ដើម្បីប្រាប់ ថាតើនរណាម្នាក់មាន**ជម្ងឺរបេង** (TB) ការធ្វើតេស្តផ្សេងៗដូចជា ការឆ្លុះអេក្វូដើមទ្រូង និងគំរូនៃ កំហាក ( ស្លេស្មដែលត្រូវបានក្អកចេញពីក្នុងសួតជ្រៅ ) អាចនឹង ត្រូវការ ។










http://www.cdc.gov/tb



CS232274_B